# របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម

**កម្មវិធីរបស់ The Asian International Justice Initiative**

ឆ្នាំទី១ លេខ ១៥ សប្តាហ៍ទី១៥ (០៣-០៦ សីហា ឆ្នាំ២០០៩)

## "សវនាការអង្គសេចក្តីលើករណីអតីតប្រធានមន្ទីរ ស-២១ កាំង ហ្គិចអាវ ហៅ ឌុច"



*រូបភាព : សាក្សីជំនាញ* ***David Chandler***

## ១. សេចក្តីផ្តើម

*ខ្ញុំមិនចូលចិត្តមនុស្ស ដែលលើកឡើងថា "យើងមិនត្រូវឱនក្បាលទៅប្រព្រឹត្តអំពើអាក្រក់ដល់ថ្នាក់នេះសោះ" ។ យើងមិនដឹងនូវអ្វី ដែលយើងនឹងត្រូវធ្វើក្នុងស្ថានភាពដូចគ្នានេះទេ ។ ការគិតថា ខ្លួនឯងមានភាពបរិសុទ្ធជាងគម្ពីរសាសនា ជាប្រការមួយមិនគួរឱ្យសរសើរទាល់តែសោះក្នុងលក្ខណៈជាមនុស្សជាតិ ។*[១]

កាលវិភាគ ១៥សប្តាហ៍ នៃកិច្ចដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម សប្តាហ៍នេះអង្គជំនុំជម្រះបានសម្រេចអានកំណត់ហេតុស្តាប់ចម្លើយសាក្សីជំនួសការផ្តល់សក្ខីកម្មដោយផ្ទាល់ ដើម្បីជំរុញកិច្ចនីតិវិធីឱ្យកាន់តែឆាប់រហ័ស ។ កំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន៥រូប ត្រូវបានអាន កាលពីថ្ងៃច័ន្ទ ដល់ ថ្ងៃពុធ ដែលសាក្សីទាំងនោះសុទ្ធតែជាអតីតបុគ្គលិកមន្ទីរ ស-២១ ។ នៅថ្ងៃព្រហស្បត្តិ៍ សាក្សីជំនាញលោក **David Chandler** បានផ្តល់សក្ខីកម្មខ្លួនពាក់ព័ន្ធនឹងសៀវភៅ *"សំលេងចេញពីមន្ទីរ ស-២១" ភាពតក់ស្លុត និងប្រវត្តិនៅគុកសម្ងាត់របស់* ***ប៉ុល ពត*** ។

## ២. បញ្ហាច្បាប់ និងនីតិវិធី

### ក. សេចក្តីសង្ខេបសក្ខីកម្ម

[1] សាក្សីជំនាញ David Chandler កំឡុងពេលសួរដេញដោលដោយមេធាវីការពារក្តីអន្តរជាតិនៅថ្ងៃប្រហស្បត្តិ៍ ទី៧ ខែសីហា ឆ្នាំ២០០៩ ។

## ***សាក្សីអតីតបុគ្គលិកមន្ទីរ ស-២១***

បន្ទាប់ពីផ្តល់សក្ខីកម្មសង្ខេបលើកំណត់ហេតុស្តាប់ចម្លើយសាក្សីអតីតបុគ្គលិកមន្ទីរ ស-២១ ខាងក្រោមនេះជាសក្ខីកម្មត្រូវមកផ្តល់ និងអានចំពោះមុខអង្គសវនាការ :

- សាក្សីលោក **សេក ដន** ជាអតីតកុមារពេទ្យ ( ផ្តល់សក្ខីកម្មនៅតុលាការ)
- សាក្សីលោក **ឡាច មាន** ជាអ្នកយាម, អ្នករដ្ឋបាល និងអ្នកសួរចម្លើយ ( ផ្តល់សក្ខីកម្មនៅតុលាការ)
- សាក្សីលោក **ជាម សឿ** ជាអតីតអ្នកយាម ( ផ្តល់សក្ខីកម្មនៅតុលាការ)
- សាក្សីលោក **ខៀវ យ៉េត** ជាអតីតអ្នមយាមក្នុងបន្ទប់ឃុំឃាំង ( អានកំណត់ហេតុស្តាប់ចម្លើយ)
- សាក្សីលោក **ប៉េស ម៉ាប់** ជាអតីតអ្នកយាមខាងក្នុង និងខាងក្រៅមន្ទីរ ស-២១ ( អានកំណត់ហេតុស្តាប់ចម្លើយ)
- សាក្សីលោក **ញ៉ែម អេន** ជាអតីតអ្នកថតរូបមន្ទីរ ស-២១ ( អានកំណត់ហេតុស្តាប់ចម្លើយ)
- សាក្សីលោក **ចៀប ហួរ** ជាអតីតអ្នកយាមក្នុងបន្ទប់ឃុំឃាំង ( អានកំណត់ហេតុស្តាប់ចម្លើយ)
- សាក្សីលោក **គង់ ផៃ** ជាអតីតអ្នកយាមខាងក្រៅមន្ទីរឃុំឃាំង ( អានកំណត់ហេតុស្តាប់ចម្លើយ)

***លក្ខខណ្ឌនៃការឃុំឃាំង :*** ជាទូទៅ ឯកសារភស្តុតាងបានផ្តល់ឱ្យដឹងពីលក្ខខណ្ឌនៃការឃុំឃាំងនៅមន្ទីរ ស-២១ បញ្ជាក់ដោយសាក្សីផ្សេងទៀត ប៉ុន្តែគួរកត់សម្គាល់ ការផ្តល់សក្ខីកម្មលម្អិតលើលក្ខខណ្ឌឃុំឃាំង សាក្សី **ឡាច មាន** បានពិពណ៌នាពីរបបអាហាររបស់អ្នកទោស គឺទទួលបានតែបបររាវៗ ។ ចំណែកកំណត់ហេតុស្តាប់ចម្លើយសាក្សី **ចៀប ហួរ** កត់សម្គាល់ពី ស្ថានភាពជាប់ឃុំរបស់អ្នកទោសនៅបន្ទប់ឃុំឃាំងតូចៗ គឺជើងជាប់ខ្នោះ ។ បន្ថែមលើនេះ សក្ខីកម្មលោក **សេក ដន** បានឱ្យដឹងថា ការព្យាបាលអ្នកទោស គឺក្នុងគោលបំណងពន្យាការស្លាប់ ដើម្បីបញ្ចប់ចម្លើយសារភាពប៉ុណ្ណោះ ។ គាត់ចងចាំទៀតថា អ្នកទោសត្រូវព្យាបាលដោយ *"ការចាក់ទឹកអំបិលលើស្នាមរបួស"* ដើម្បីឱ្យឆាប់ជាសះស្បើយ ។

***ការសួរចម្លើយ និងការធ្វើទារុណកម្ម :*** សាក្សី **សេក ដន, ខៀវ យ៉េត**, និង **ចៀប ហួរ** បានអះអាងថា ពួកគេមិនបានឃើញការធ្វើទារុណកម្មដោយផ្ទាល់ភ្នែកទេ ប៉ុន្តែបានឃើញអ្នកទោសមានរបួសជាច្រើន ដូចជា ស្នាមរំពាត់ ការដកក្រចក ការឆក់ខ្សែភ្លើងជាដើម ។ម្យ៉ាងទៀត សាក្សី **ឡាច មាន** បានអះអាងថា បានឃើញផ្ទាល់ភ្នែក និងចូលរួមធ្វើទារុណកម្ម និងរៀបរាប់ថា ត្រចៀកអ្នកទោសត្រូវឆក់ខ្សែភ្លើង វាយនឹងរំពាត់មែកឈើ... ប៉ុន្តែគាត់មិនបានឃើញអ្នកសួរចម្លើយប្រើថង់ផ្លាស់ទ្និក ឬបច្ចេកទេសបញ្ជ្រកទឹកអ្នកទោស កំឡុងពេលសួរចម្លើយទេ ។

***ការកំទេចចុងក្រោយជាទ្រង់ទ្រាយធំ :*** កំណត់ហេតុស្តាប់ចម្លើយសាក្សី **គង់ ផៃ** និង **ចៀប ហួរ** បានពិពណ៌នាលម្អិតពីហេតុការណ៍

កើតឡើងមុនថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ អំពីការសម្លាប់រង្គាលនៅបរិវេណមន្ទីរ ស-២១ និងការសម្លាប់ទ្រង់ទ្រាយធំចុងក្រោយនៅក្រៅមន្ទីរសន្តិសុខ ។ កំណត់ហេតុទាំងពីរបានលើកឡើងថា អ្នកទោសត្រូវបានដឹកជញ្ជូនទៅវាលពិឃាតជើងឯក ។

***គោលនយោបាយសម្ងាត់ :*** នាសប្តាហ៍នេះ ភស្តុតាងបានបង្ហាញថា គោលនយោបាយសម្ងាត់ត្រូវជ្រួតជ្រាបគ្រប់អង្គភាពប្រតិបត្តិនៅមន្ទីរ ស-២១ ។ សាក្សី **ឡាច មាន** និង **ខ្សេវ យ៉េត** បានពិពណ៌នាពីរបៀបដែលបុគ្គលិកមន្ទីរ ស-២១ ត្រូវហាមឃាត់មិនឱ្យទាក់ទងមនុស្សខាងក្រៅ រួមទាំង គ្រួសារ និងមិត្តភ័ក្ត្រ ។ កំណត់ហេតុស្តាប់ចម្លើយសាក្សី **ញ៉ែម អៀន** ក៏បានរៀបរាប់ពីរបៀបអ្នកថតរូបមិនត្រូវបានអនុញ្ញាតឱ្យផ្តិតរូបដែលខ្លួនថតបាន ។ ការបែងចែកកាពត្វកិច្ចនេះ គឺហាមឃាត់មិនឱ្យពួកគេដឹងគោលនយោបាយសម្ងាត់ទាំងនោះ ។ សិទ្ធិដើរហើររបស់បុគ្គលិកក៏ត្រូវរឹតត្បិតនៅការិយាល័យសន្តិសុខ ។ សាក្សី **ជាម សឿ** បានបញ្ជាក់ថា កំឡុងជាប់កាតព្វកិច្ចសម្លាប់អ្នកទោស បុគ្គលិកមិនត្រូវបានអនុញ្ញាតឱ្យចាកចេញពីទីកន្លែងដែលបានកំណត់ទេ ។ (សាក្សីបញ្ជាក់ថា នេះជាហេតុផលដែលគាត់មិនធ្លាប់បានចូលបរិវេណមន្ទីរឃុំឃាំង) ។

***បរិយាកាសនៃការភ័យខ្លាច :*** នាសប្តាហ៍នេះ សាក្សីផ្តល់សក្ខីកម្មថា បរិយាកាសភ័យខ្លាចមានជាទូទៅនៅមន្ទីរ ស-២១ ។ សាក្សីលើកថា ការប្រព្រឹត្តកំហុសតូចតាចក៏អាចធ្វើឱ្យមនុស្សស្លាប់ដែរ ។ ជាពិសេស សាក្សី **សេក ដន** បានពិពណ៌នាពីភាពភ័យខ្លាចរបស់គាត់ ខណៈធ្វើការនៅការិយាល័យសន្តិសុខ គឺខ្លាចត្រូវចាប់ខ្លួន និងសម្លាប់ថ្ងៃណាមួយ ។ ស្រដៀងគ្នានេះដែរ កំណត់ហេតុស្តាប់ចម្លើយសាក្សី **ញ៉ែម អេន** និង **ចៀប ហួរ** បានបង្ហាញថា បុគ្គលិកត្រូវប្រកាន់ខ្ជាប់កាតព្វកិច្ចខ្លួន ដោយព្យាយាម និងអត់ធ្មត់ តែត្រូវគោរពតាមបទបញ្ជា ។

***ការបោសសំអាតនៅមន្ទីរ ស-២១ :*** សាក្សីអតីតបុគ្គលិកមន្ទីរ ស-២១ បានរៀបរាប់ពីវិធីសម្លាប់បុគ្គលិកមន្ទីរ ស-២១ ។ សាក្សី **សេក ដន** លើកឡើងថា ប្រធានបុគ្គលិកពេទ្យលោក **ប៉ោរ** ត្រូវចាប់ខ្លួន នៅពេលមានអ្នកទោសប្រតិកម្មថ្នាំ បន្ទាប់ពីគាត់បានចាក់ថ្នាំរួច។ គាត់បន្តថ្លែងថា គាត់ត្រូវចាប់ខ្លួនក្រោមបញ្ជារបស់ **ឌុច** ។ សាក្សី **ឡាច មាន** បានផ្តល់សក្ខីកម្មថា បុគ្គលិកមន្ទីរ ស-២១ រួមមាន ប្រធាន និងបុគ្គលិកអង្គភាព ត្រូវបាត់ខ្លួនជាបន្តបន្ទាប់ ។ ស្រដៀងគ្នានេះដែរ សាក្សី **ជាប សឿ** បានពិពណ៌នាថា ថ្នាក់លើលោក **ហុង** បានហៅគាត់ទៅប្រជុំនៅបរិវេណមន្ទីរសន្តិសុខ ប៉ុន្តែការពិតនាំទៅចាប់ខ្លួន ។

***អ្នកទោសបរទេស :*** នាសប្តាហ៍នេះ សាក្សីបានបញ្ជាក់ពីវត្តមានអ្នកទោសជនជាតិវៀតណាមនៅមន្ទីរ ស-២១ ។ សាក្សី **ឡាច មាន** សាក្សី **ញែម អេន** និង សាក្សី **គង់ ផៃ** បានអះអាងថា ពួកគេបានឃើញជនជាតិវៀតណាមចូលមន្ទីរ ស-២១ ទោះជាចំនួនខុសគ្នាក៏ដោយ ។ សាក្សី **ឡាច មាន** អះអាងថា បានឃើញអ្នកទោសជនជាតិវៀតណាមប្រហែលជា ១០០ ទៅ ២០០ នាក់ ។ ចំណែកសាក្សី **ញែម អេន** បានឃើញប្រហែល **២០នាក់** ខណៈសាក្សី **គង់ ផៃ** បានថ្លែងថា គាត់មិនធ្លាប់ឃើញជា *"លក្ខណៈទ្រង់ទ្រាយធំ"* ទេ ។ ចំពោះ អ្នកទោសបស្ចិមប្រទេស លោក **គង់ ផៃ** អះអាងថា គាត់បានឃើញជនជាតិអាមេរិក ៣ រូប នាំចូលតាមច្រកខាងត្បូងមន្ទីរ ស-២១ ។ សាក្សី **ញែម អៀន** បានអះអាងថា គាត់បានឃើញអ្នកទោសបរទេសក្នុងចំនួននេះ ប៉ុន្តែមិនដឹងពី

សញ្ជាតិរបស់ពួកគេទេ ។ បន្ថែម លើនេះ លោក **ជាម សឿ** បានពិពណ៌នាពីការដុតសម្លាប់អ្នកទោសបរទេសម្នាក់នៅខាងក្រៅបរិវេណមន្ទីរ ស-២១ ។

***វគ្គរៀនសូត្រ និងអង្គប្រជុំ :*** លោក **សេក ដន** និងលោក **ជាម សឿ** បានអះអាងថា ពួកគេមិនធ្លាប់បានចូលរួមវគ្គរៀនសូត្រនយោបាយទេ ប៉ុន្តែបានចូលរួមប្រជុំស្វ័យទិះតៀនម្តងក្នុងក្រុមខ្លួន ។ សាក្សីផ្សេងៗបានរៀបរាប់ថា ខ្លួនធ្លាប់ចូលរួមវគ្គរៀនសូត្រនយោបាយ ។ លោក **ញ៉ាប ហូ** បានបញ្ជាក់ថា កំឡុងពេលចាត់តាំងការងារនៅមន្ទីរ ស-២១ គាត់បានចូលរួមវគ្គរៀនសូត្រម្តងនៅអគារក្បែរផ្ទះ**ឌុច** តែវគ្គនោះ **ឌុច** មិនបបានបង្រៀនទេ ។ ម្យ៉ាងទៀត លោក **គង់ ផៃ** បរិយាយថា គាត់បានចូលរួមរៀនសូត្រ ២វគ្គ ដែលឧទ្ទេសនាមដោយ**ឌុច** អំពីវិធីការពារមិនឱ្យអ្នកទោសរត់គេចខ្លួន លក្ខន្តិកៈបក្ស និងការធ្វើសង្គ្រាមជាមួយវៀតណាម ។ លោក **ខៀវ យ៉េត** ក៏បានឃើញជនជាប់ចោទ ២ដង នៅវគ្គអប់រំដែលគាត់ចូលរួម ។

***តួនាទីជនជាប់ចោទនៅមន្ទីរ ស-២១ :*** នាសប្តាហ៍នេះ សាក្សីអតីតជាបុគ្គលិកមន្ទីរ ស-២១ បានអះអាងថា មិនធ្លាប់ទទួលបញ្ជាផ្ទាល់ពី **ឌុច** ទេ បើទោះបីជាដឹងថា **ឌុច** មានតួនាទីខ្ពស់ជាងគេនៅការិយាល័យសន្តិសុខក៏ដោយ ។ សាក្សីម្នាក់បានអះអាងយ៉ាងច្បាស់ថា ធ្លាប់ទទួលបញ្ជាដោយផ្ទាល់ពី **ឌុច** គឺសាក្សី **ញ៉ែម អេន** ។ អតីតអ្នកថតរូបនៅមន្ទីរ ស-២១ បានពិពណ៌នាថា បញ្ជា **ឌុច** គឺ *"តឹងរឹង"* និង *"ធ្វើមិនឱ្យមានកំហុស"* ។ សាក្សីរូបនេះបានសន្និដ្ឋានថា ទោះបីជា **ឌុច** ទំនងជាទទួលបញ្ជាពី **សុន សេន** ក៏ពួកគេ *"ដូចតែគ្នា"* ។ គាត់អះអាងបន្ថែមថា **ឌុច** បានរាយការណ៍ដោយផ្ទីតផ្ទង់ទៅ **សុន សេន** , **ប៉ុល ពត** និង **នួន ជា** ដោយធ្វើឱ្យពួកគេសម្រេចថា នរណាត្រូវកំទេច ។ តាមសក្ខីកម្មនេះ **ឌុច** ជាអ្នកផ្តល់ភ្លើងខៀវដល់ **សុន សេន** និង **ប៉ុល ពត** ។

## សក្ខីកម្មលោក David Chandler

នាថ្ងៃព្រហស្បតិ៍នេះ អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មសាក្សីជំនាញលោក ***David Chandler*** អ្នកប្រវត្តិសាស្ត្រ អាយុ ៧៦ឆ្នាំ និងជំនាញផ្នែកប្រវត្តិសាស្ត្រកម្ពុជា ផ្តោតលើសម័យកម្ពុជាប្រជាធិបតេយ្យ ។ លោក ***Chandler*** គឺជាអ្នកនិពន្ធសៀវភៅ *"សំលេងចេញពីមន្ទីរ ស-២១ : ភាពតក់ស្លុត និងប្រវត្តិគុកសម្ងាត់របស់ ប៉ុល ពត"* ដែលសៀវភៅនេះចំណាយពេលច្រើនរហូតដល់ ៤ឆ្នាំ ក្នុងការសិក្សាស្រាវជ្រាវនៅបណ្ណសារមន្ទីរ ស-២១ និងកិច្ចសម្ភាសន៍នៅកំឡុងទស្សវត្សឆ្នាំ ១៩៩០ ។ អង្គជំនុំជម្រះ និងភាគីនានា បានសួរដេញដោលលោក ***Chandler*** អំពីសៀវភៅនេះ ដោយផ្តោតសំខាន់លើចរិកលក្ខណៈមន្ទីរស-២១ និងតួនាទីជនជាប់ចោទ នៅការិយាល័យសន្តិសុខ ។

***តួនាទីមន្ទីរ ស-២១ :*** យោងតាមលោក ***Chandler*** ទស្សនទានថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរ ស-២១ មានលក្ខណៈខុសប្លែកពីការិយាល័យសន្តិសុខ ឬមន្ទីរឃុំឃាំងនានារបស់របបនេះ ។ លោក ***Chandler*** បានអះអាងថា មានលក្ខណៈពិសេសខុសគ្នាពីរសំខាន់នៃ *"ស្ថាប័នទាំងមូល"* គឺទី១ : អាណត្តិ និងប្រតិបត្តិការមន្ទីរ ស-២១ ត្រូវឈរលើគោលការណ៍រក្សាការសម្ងាត់ ។ ទី២ : អ្នកទោសនៅមន្ទីរ ស-២១ ស្ថិតក្នុងគោលដៅអប់រំកែប្រែឱ្យមានប្រសិទ្ធិភាព គឺកំទេច (ការរក្សាអ្នកទោស គឺត្រឹមតែ

ទាញយកចម្លើយសារភាព និងការសារភាពកំហុស ដែលបង្កើតជា *"ការអប់រំកែប្រែឡើងវិញ"*)។ ចំពោះលោក **Chandler** មហាសោកនាដកម្មនៃស្ថាប័ននេះ ជាលទ្ធផល គឺជាម៉ាស៊ីនប្រព្រឹត្តអំពើបទឧក្រិដ្ឋ ព្រោះមនុស្សបញ្ជូនទៅមន្ទីរ ស-២១ ស្ទើរតែទាំងអស់ ចៀសមិនផុតពីការសម្លាប់ឡើយ ។

## មុខងារមន្ទីរ ស-២១

***ការសួរចម្លើយ :*** តាមទស្សនៈលោក **Chandler** ជាការពិត មនុស្សគ្រប់រូបបញ្ជូនទៅមន្ទីរ ស-២១ ត្រូវចាត់ថាមានទោស *"បញ្ជាក់ដោយអ្នកសួរចម្លើយ"* ។ ទោះបីជាយ៉ាងណាក៏ដោយ ការលាតត្រដាងនូវភស្តុតាងអាចធ្វើឱ្យជនជាប់ចោទកាន់តែមានស្ថានទំងន់ទោស លោក **Chandler** បញ្ជាក់ថា គាត់បានសិក្សាលើឯកសារជាច្រើនបង្ហាញពីការសរសើររបស់ **ឌុច** លើចម្លើយសារភាព ដែលមិនទទួលដោយសារការធ្វើទារុណកម្ម ។ ផ្អែកតាមការវាយតំលៃរបស់ **Chandler** លើចម្លើយសារភាពគួរឱ្យពេញ ចិត្ត មានន័យថា អាចប្រើទារុណកម្មជាអប្បបរមា ឬក៏គ្មាន ។

***ទារុណកម្ម :*** លោក **Chandler** ត្រូវបានសួរដេញដោលអំពីការពិពណ៌នាពីការប្រព្រឹត្តិលើអ្នកទោស ដែលសរសេរក្នុងសៀវភៅ និង សួរបញ្ជាក់អំពីមូលហេតុបច្ចេកទេសធ្វើទារុណកម្ម ដែលគាត់គិតថា អាចត្រូវបានប្រើ ។ សាក្សីបានបញ្ជាក់ថា ការអនុវត្តន៍ជាក់ស្តែងនូវទារុណកម្មមិនបានបញ្ចូលក្នុងច្បាប់អន្តរជាតិទេ ប៉ុន្តែផ្អែកប្រព្រឹត្តលើអ្នកទោស គឺស្របតាមនិយមន័យនៃលិខិតុបករណ៍ច្បាប់អន្តរជាតិ ។ គាត់បានទទួលស្គាល់ថា លក្ខខណ្ឌឃោរឃៅនៅមន្ទីរ ស-២១ បង្កើតជាប្រព័ន្ធ *"បំបាក់ស្មារតី"* ក្នុងគោលបំណងទទួលបានព័ត៌មានតាមការសួរចម្លើយ ។ តាមប្រសាសន៍ លោក **Chandler** *"នៅមន្ទីរសន្តិសុខ ស-២១ គឺកាចសាហាវ និងគ្មានក្តីមេត្តាទេ"*។

***អ្នកទោសស្រ្តី និងការរំលោភផ្លូវភេទ:*** ថ្វីបើមានរំលោភបំពានផ្លូវភេទកើតឡើងដោយចៃដន្យនៅមន្ទីរ ស-២១ ក៏លោក **Chandler** បានបញ្ជាក់ថា មិនមានភស្តុតាងគាំទ្រលើទស្សនៈនោះទេ ដែលថា មន្ទីរ ស-២១ ជាកន្លែងប្រព្រឹត្តបទល្មើសនោះ *"ដោយចំហលើអ្នកទោសស្ត្រី"* ។ ខណៈទទួលស្គាល់ថា ស្ថានភាពនៅមន្ទីរ ស-២១ ងាយស្រួលផ្លាស់ប្តូរ ក៏លោក **Chandler** បានអះអាងថា **ឌុច** បានបញ្ឈប់មិនឱ្យមានសកម្មភាពបំពានផ្លូវភេទលើអ្នកទោសស្ត្រីទៀតទេ ទោះបីជាគុកនោះសំបូរដោយយុទ្ធជនក្មេងៗក៏ដោយ ។ លោក **Chandler** កត់សម្គាល់ដែរថា អ្នកទោសស្ត្រីជនជាតិវៀតណាម គឺជាក្រុមងាយរងគ្រោះបំផុតនៅមន្ទីរ ស-២១ ដោយចាត់ទុកថា *"ជាមនុស្សជាតិសាសន៍ផ្សេង"* នៅពេលជម្លោះចាប់ផ្តើមរវាងកម្ពុជាប្រជាធិបតេយ្យ និងវៀតណាម។

***ការបោសសំអាត :*** ឆ្លើយតបនឹងលោកស្រីចៅក្រម **Cartwright** លោក **Chandler** បានបំភ្លឺនូវការអះអាងរបស់ជនជាប់ចោទអំពីការបោសសំអាត២ដំណាក់កាលធំៗ (**ឧទា :** ពីឆ្នាំ១៩៧៥ ដល់ខែកញ្ញា ឆ្នាំ១៩៧៦ បោសសំអាតមនុស្សពាក់ព័ន្ធនឹងរបបមុន និងពីឆ្នាំ១៩៧៦ រហូតដល់ចុងបញ្ចប់មន្ទីរ ស-២១ បោសសំអាតលើកម្មាភិបាលខ្មែរក្រហម) ។ គាត់កត់សម្គាល់ថា មនុស្សមួយចំនួនទំនងជាបោសសំអាត ដោយសារប្រឆាំងនឹងរបបនេះយ៉ាងពិតប្រាកដ ។

***ចម្លើយសារភាព :*** លោក ***Chandler*** បានអះអាងថា សុក្រឹត្យភាពនៃចម្លើយសារភាពរបស់អ្នកទោសស្ថិតក្នុង *"ក្តីកង្វល់តូចមួយ"* ចំពោះថ្នាក់លើ ។ ចំពោះបញ្ជីជនក្បត់ត្រូវបញ្ចេញឱ្យដឹងដោយអ្នកទោសដែលត្រូវបានសួរចម្លើយ សាក្សីជឿជាក់ថា ជាទូទៅអ្នកទោសត្រូវបង្ខំឱ្យប្រាប់ឈ្មោះមនុស្សដែលពួកគេស្គាល់ ដោយមិនគិតថាជា *"សត្រូវ"* ពិតប្រាកដទេ ។ សាក្សីបានសន្និដ្ឋានថា ការងារទាំងអស់ធ្វើឡើងបំពេញតំរូវចិត្តថ្នាក់ដឹកនាំ ដើម្បីឱ្យស្របច្បាប់ដំផ្តួលលីលានៅសម័យនោះ ដោយការរំខានឥតឈប់ឈរពីខ្មាំងស៊ីរូងផ្ទៃក្នុង និងខ្មាំងក្រៅបក្ស ។

## អត្តចរិត និងការជាប់ពាក់ព័ន្ធរបស់ឌុច

***អត្តចរិកជនជាប់ចោទ :*** លោក ***Chandler*** បានទទួលស្គាល់ថា គាត់មិនដែលសម្ភាសន៍ **ឌុច** ដោយផ្ទាល់ទេ ការវិភាគអំពីតួនាទី **ឌុច** ក្នុងប្រតិបត្តិការនៅមន្ទីរ ស-២១ និងអត្តចរិកជនជាប់ចោទ ដោយផ្អែកលើការសម្ភាសន៍ធ្វើឡើងជាមួយអតីតបុគ្គលិកមន្ទីរ ស-២១ និងជនរងគ្រោះ ព្រមទាំងសិក្សាលើឯកសារនានានៅមន្ទីរស-២១ ។ **ឌុច** មាន *"ការម៉ុងលំ និងមោទនភាពចំពោះវិជ្ជាជីវៈខ្លួន"* ហើយចង់ឱ្យថ្នាក់ដឹកនាំមើលឃើញពីគុណសម្បត្តិមន្ទីរស-២១ និងបណ្តាសហគមន៍អន្តរជាតិចាត់ទុកថា *"ជាស្ថានប័នជំនាញមានប្រសិទ្ធិភាពខ្ពស់"* ។ ស្របនឹងបំណងប្រាថ្នារបស់ជនជាប់ចោទ មិនត្រឹមតែបំពេញការងារដោយក្តីពេញចិត្តទេ ថែមទាំងធ្វើឱ្យល្អវិសេស គឺការច្នៃប្រឌិតថ្មី និងលើកកំពស់ការគ្រប់គ្រងនៅមន្ទីរ ស-២១ ។

***ការយល់ដឹង :*** យោងតាមលោក ***Chandler*** បញ្ហាតិចណាស់ដែលគេចផុតពីការចាប់អារម្មណ៍របស់ **ឌុច** ។ **ឌុច** ទទួលបានព័ត៌មានគ្រប់បញ្ហាកើតឡើងនៅមន្ទីរ ស-២១ តាមរយៈបុគ្គលិកក្រោមបង្គាប់គាត់ ។ ការនេះនាំឱ្យ **ឌុច** បានដឹង និងដាក់ពិន័យលើអ្នកសួរចម្លើយ ដែលមិនបំពេញការងារបានល្អ ឬមិនគោរពតាមមាគ៌ាបក្ស ។

***ភាពខុសប្លែកបង្កើតឡើងដោយឌុច :*** លោក ***Chandler*** មិនទទួលយកគំនិតដែលថា **ឌុច** គឺជាមនុស្សតែម្នាក់ផ្តួចផ្តើមឱ្យមានការប្រព្រឹត្តសកម្មភាពផ្សេងៗនៅមន្ទីរ ស-២១ ទេ ។ លោកបានពន្យល់ថា បញ្ហានេះស្របនឹងចរិកលក្ខណៈរបស់បដិវត្តន៍ចិន និងកម្ពុជា ដែលប្រជាជនត្រូវផ្តល់សិទ្ធិសេរីភាពគោរពតាម *"ទិសដៅបដិវត្តន៍"* ។ ចំនុចនេះទំនងជានាំឱ្យបុគ្គលិកក្រោមបង្គាប់ **ឌុច** អាចច្នៃប្រឌិតដោយខ្លួនឯងនូវរបៀប និងវិធីផ្សេងៗកំឡុងពេលសួរចម្លើយ ។

***បញ្ហានៃជម្រើស?*** ការលើកឡើងនូវលទ្ធភាពដែលថា សកម្មភាពរបស់ **ឌុច** គឺស្ទើរតែគ្មានជម្រើសនោះ លោក ***Chandler*** បានបង្ហាញថា **ឌុច** បានដឹងពីមហន្តរាយផ្សេងៗកើតចេញពីសកម្មភាពខ្លួន ប៉ុន្តែដោយការពេញចិត្តចំពោះការងារ ធ្វើឱ្យគាត់មិនខ្លាចក្រែងក្នុងការប្រតិបត្តិតាម ។ គាត់នៅតែទទួលស្គាល់ថា ឯកសារបញ្ជាក់ថា **ឌុច** បានណែនាំឱ្យប្រើ *"នយោបាយ"* ជំនួសការធ្វើទារុណកម្ម ។ ជាពិសេស លោក ***Chandler*** យល់ស្របថា កម្មាភិបាលជាន់ខ្ពស់អាចប្រើអំណាចឆន្ទានុសិទ្ធិការពារមនុស្សដែលខ្លួនពេញចិត្ត ។ ភស្តុតាងបានបង្ហាញថា ប្រពន្ធ័ជួយឧបត្ថម្ភតាមខ្សែរយៈបែបនេះ មានពាសពេញផ្ទៃប្រទេសកម្ពុជានាសម័យនោះ ។

*ទស្សនៈវិស័យប្រវត្តិសាស្ត្រជាក់លាក់ :* តាមសក្ខីកម្មលើកឡើងមុន ដែលផ្តល់ដោយលោក **François Bizot** លោក ***Chandler*** បានលើកឡើងថា ទោះបីជាឥរិយាបទរបស់ជនជាប់ចោទមិនអាចអត់ទោសបាន តែយើងអាចយល់បានក្នុងកម្រិតមួយ ។ តាមរយៈបទពិសោធន៍ពីការសិក្សាសោកនាដកម្មកើតមាននៅរបបខ្មែរក្រហម លោក ***Chandler*** បានកត់សម្គាល់ថា អំពើអមនុស្សធម៌ដែលកើតឡើងនៅមន្ទីរ ស-២១ គឺជាចារិកលក្ខណៈនៃបាតុភូតសកល បើទោះបីជាយើងចង់ទប់ស្កាត់ក៏ដោយ ។ គាត់ណែនាំថា *មនុស្ស ស្ទើរតែគ្រប់រូបអាចត្រូវប្រព្រឹត្តអំពើឃោរឃៅដូចគ្នា ប្រសិនបើស្ថិតក្នុងស្ថានភាពដូចគ្នា* ។

## ២. អំណះអំណាង និងកង្វល់ក្នុងសវនាការ

*ការលើកឡើងជាថ្មីអំពីកំណត់ហេតុស្តាប់ចម្លើយសាក្សីធ្វើដោយមជ្ឈមណ្ឌលឯកសារកម្ពុជា :* ការប្រើប្រាស់កំណត់ហេតុសម្ភាសន៍សាក្សីធ្វើដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវលើកឡើងជាថ្មី នៅថ្ងៃអង្គារ ដែលសហព្រះរាជអាជ្ញាជាតិប៉ុនប៉ងសួរដេញដោលសាក្សីលោក **ឡាច មាន** អំពីព័ត៌មានផ្តល់ឱ្យទៅអង្គការសង្គមស៊ីវិល ។ សហមេធាវីការពារក្តីអន្តរជាតិលោក **Roux** បានបញ្ជាក់ជាថ្មី អំពីការជំទាស់នឹងការប្រើប្រាស់ព័ត៌មានទាំងនេះ ដោយសំអាងថា កិច្ចសម្ភាសន៍ក្រៅពីបរិបទតុលាការមិនគួរសម្រិតសម្រាំងជាភស្តុតាងក្នុងសវនាការទេ ។ អង្គជំនុំជម្រះបានច្រានចោលការជំទាស់នេះ ដោយលោកចៅក្រម **Lavergne** លើកឡើងថា រាល់របាយការណ៍ផ្តល់ដោយអង្គការសង្គមស៊ីវិល គឺអនុញ្ញាតិឱ្យប្រើប្រាស់បាន ដើម្បីសួរដេញដោលសាក្សីពីលក្ខខណ្ឌបង្កើតរបាយការណ៍នោះ ។

*កំណត់ហេតុស្តាប់ចម្លើយសាក្សីធ្វើសម្បថត្រូវបានបញ្ជាក់ :* បន្ទាប់ពីបញ្ចប់សក្ខីកម្មសាក្សី **ឡាច មាន** នៅថ្ងៃអង្គារ ប្រធានអង្គជំនុំជម្រះ បានប្រកាសថា កិច្ចនីតិវិធីបន្តបន្ទាប់នៅថ្ងៃនេះ គឺអានកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលបានធ្វើសម្បថ ហើយអង្គជំនុំជម្រះសម្រេចមិនកោះហៅសាក្សីនោះឱ្យផ្តល់សក្ខីកម្មទេ ។ អង្គជំនុំជម្រះកំណត់ថា នីតិវិធីអានកំណត់ហេតុស្តាប់ចម្លើយ មានដូចតទៅ : បន្ទាប់ពីក្រឡាបញ្ជីអានកំណត់ហេតុនោះរួច ភាគីមានឱកាសផ្តល់ការសង្កេតរបស់ខ្លួន បន្ទាប់មកជនជាប់ចោទនឹងត្រូវអនុញ្ញាតឱ្យផ្តល់យោបល់ ប្រសិនបើមានបំណង ។

*មេធាវីការពារក្តីស្នើកាត់បន្ថយសាក្សីចេញពីបញ្ជី និងភស្តុតាង :* នៅក្នុងកិច្ចខិតខំប្រឹងប្រែងបង្កើនល្បឿនកិច្ចនីតិវិធី អង្គជំនុំជម្រះ បន្តអនុញ្ញាតឱ្យអានកំណត់ហេតុស្តាប់ចម្លើយសាក្សីនាសប្តាហ៍នេះ ជំនួសការផ្តល់សក្ខីកម្មនៅសវនាការ ក៏ប៉ុន្តែមេធាវីការពារក្តីលើកឡើងពីកង្វល់ព័ត៌មានច្រំដែល ដោយបញ្ជាក់ថា អង្គហេតុជាច្រើនក្នុងកំណត់ហេតុទាំងនោះ ជាអង្គហេតុដែលជនជាប់ចោទមិនជំទាស់ក្នុងដីការបញ្ជូនរឿងឱ្យស៊ើបសួរ ។ មេធាវីការពារក្តីអន្តរជាតិលោក **Roux** បានស្នើជាបន្តបន្ទាប់ ដោយសំអាងលើវិធាន ៨៥ និងវិធាន ៨៧ នៃវិធានផ្ទៃក្នុង ក្នុងការច្រានចោលសក្ខីកម្មមួយចំនួន ដែលកំណត់ហេតុទាំងនោះមានព័ត៌មានច្រំដែល និងមិនឆ្លុះបញ្ចាំងពីការពិត ។ សហព្រះរាជអាជ្ញាអន្តរជាតិលោក **Anees Ahmed** បានលើកឡើងថា ភស្តុតាងទាំងនោះមិនច្រំដែលទេ ប៉ុន្តែជាព័ត៌មានទូទៅសម្រាប់សំណុំរឿងបទឧក្រិដ្ឋធំៗ ។ គាត់ស្នើបន្ថែមថា ប្រសិនបើមេធាវីការពារក្តីចង់ឱ្យ

កិច្ចនីតិវិធីប្រព្រឹត្តទៅ ឆាប់រហ័ស គួរអានសេចក្តីសង្ខេបកំណត់ហេតុសាក្សី ជំនួសការអានទាំងមូល ។ អង្គជំនុំជម្រះ បានប្រកាសថា កាលវិភាគនឹងកំណត់ឡើងវិញ ថាតើសាក្សីណាខ្លះត្រូវកាត់ចេញពីបញ្ជីឈ្មោះ និងកំណត់ហេតុណាខ្លះត្រូវអានទាំងមូល ឬដោយសង្ខេប ។ ទោះបីយ៉ាងណា ប្រធានអង្គជំនុំជម្រះបន្ថែមថា កាលវិភាគបច្ចុប្បន្ននៅតែអនុវត្ត ដរាបណាមិនទាន់មានការកែប្រែថ្មី ។

***ការកំណត់ជាមុនលើការប្រើប្រាស់ចម្លើយសារភាពបានមកពីការធ្វើទារុណកម្ម :*** នៅថ្ងៃព្រហស្បតិ៍ ការសួរដេញដោលសាក្សីជំនាញ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិក្រុម២ លោកស្រី **Studzinsky** លើកឡើងពីចម្លើយសារភាពមន្ទីរ ស-២១ បានមកពីអតីតអ្នកសួរចម្លើយ ។ មេធាវីការពារក្តីលោក **François Roux** ភ្លាម១នោះ បានរំលឹកដល់អង្គជំនុំជម្រះពីការណែនាំមុនថា ខ្លឹមសារចម្លើយសារភាពដែលបានពីការធ្វើទារុណកម្ម មិនគួរប្រើប្រាស់នៅសវនាការឡើយ ដូចមានចែងក្នុងកតិកាសញ្ញាអន្តរជាតិ ប្រឆាំងការធ្វើទារុណកម្ម ។ ប្រធានអង្គជំនុំជម្រះលោក **និល ណុន** ទទួលយកការជំទាស់ ហើយមិនផ្តល់ឱកាសឱ្យលោកស្រី **Studzinsky** បកស្រាយពីសំណួរនោះ តើទាក់ទងនឹងខ្លឹមសារចម្លើយសារភាព ឬទិដ្ឋភាពនៃឯកសារ ។ ករណីនេះ គួរកោតសរសើរអង្គជំនុំជម្រះ ក្នុងការធានាឱ្យមានការគោរពបទដ្ឋានអន្តរជាតិនៅកិច្ចនីតិវិធី ប៉ុន្តែគួរផ្តល់ឱកាសដល់ភាគីបកស្រាយលើការលើកឡើងសំណួរខ្លួន ហើយឯកសារនោះបានមកដោយលក្ខខណ្ឌអ្វី ។

***សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងខ្លួនឯង និងកាតព្វកិច្ចនិយាយការពិត :*** បន្ទាប់ពីការបង្ហាញខ្លួនសាក្សីអតីតបុគ្គលិកមន្ទីរ ស-២១ចំពោះមុខអង្គជំនុំជម្រះ បញ្ហាសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងខ្លួនឯង បានក្លាយជាកង្វល់ដ៏សំខាន់ក្នុងដំណើរការនីតិវិធី ។ នាសប្តាហ៍នេះ ទោះបីជា អង្គជំនុំជម្រះមានការរំលឹក និងពន្យល់ជាញឹកញាប់អំពីបញ្ហានេះ និងជំនួយមេធាវីប្រឹក្សាសាក្សីត្រូវបានផ្តល់ ក៏សាក្សីនៅតែលំបាកកំណត់រវាងសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងខ្លួនឯង និងកាតព្វកិច្ចនិយាយការពិត ។ **<u>ឧទា :</u>** នៅថ្ងៃចន្ទ លោក **សេក ជន** បន្តបដិសេធមិនឆ្លើយតបសំណួរមួយចំនួន ទោះបីជា ចម្លើយនោះមិនប្រឆាំងខ្លួនឯង និងមានជំនួយពីមេធាវីប្រឹក្សាយោបល់សាក្សីក៏ដោយ ។ លោកចៅក្រម **Lavergne** បានលើកឡើងដែរពីចំណុចនេះចំពោះសាក្សីលោក **ជាម សឿ** នៅថ្ងៃពុធ ដែលសាក្សីនេះបង្ហាញពីការស្ទាក់ស្ទើរក្នុងការឆ្លើយសំណួរចៅក្រម ។

## ៣. ការចូលរួម និង ការការពារសាក្សី និងជនរងគ្រោះ

***វត្តមានដើមបណ្តឹងរដ្ឋប្បវេណី :*** ដូចសប្តាហ៍មុន១ វត្តមានដើមបណ្តឹងរដ្ឋប្បវេណីមានចំនួន ៩រូប ចូលរួមក្នុងកិច្ចដំណើរការសវនាការនាសប្តាហ៍នេះ ។

***មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី :*** នៅថ្ងៃច័ន្ទ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិថ្មីក្រុម ៣ លោកស្រី **Fabienne Trusse Naprous** ត្រូវទទួលស្គាល់ដោយអង្គជំនុំជម្រះ ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៤ លោក **ហុង គីមសួន** និងលោក **យ៉ុង ផានិត** អវត្តមានកំឡុងកិច្ចដំណើរការនីតិវិធីកាលពីថ្ងៃអង្គារ ថ្ងៃពុធ និងថ្ងៃព្រហស្បតិ៍ ប៉ុន្តែលោក **គង់ ពិសី** បាន

ប្រកាសថា លោកជាតំណាងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ៤ ។

***មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបន្តកិច្ចសហការគួរឱ្យកោតសរសើរ*** : ស្របតាមការអនុវត្តន៍កាលពីសប្ដាហ៍មុន មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី នាសប្ដាហ៍នេះ បានបន្តបន្ថយចំនួនក្រុមមេធាវីក្នុងការសួរដេញដោលសាក្សី ដោយចាត់តាំងតំណាងរួម ។ នៅថ្ងៃច័ន្ទ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុម៣ បានតំណាងទាំង៤ក្រុម ។ នៅថ្ងៃអង្គារ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ១ និង ក្រុម ២ ធ្វើការសួរដេញដោលសាក្សី ។ នៅថ្ងៃពុធ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុម៣ និងក្រុម៤ ជាអ្នកទទួលបន្ទុកសួរដេញដោលសាក្សី ។ នៅថ្ងៃព្រហស្បតិ៍ ចំនួនមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីកើនឡើងរហូតដល់៣ក្រុម ធ្វើការសួរដេញដោលសាក្សី **David Chandler** ប៉ុន្តែនេះមិនមែនជារឿងភ្ញាក់ផ្អើលទេ ព្រោះលោក **David Chandler** ជាសាក្សីជំនាញ ។ ការអនុវត្តន៍ជម្រើសឱ្យមានតំណាងរួមនេះ ហាក់ធ្វើឱ្យការតាំងសំណួរមានទំនាក់ទំនងគ្នា និងកាត់បន្ថយសំណួរច្រំដែល ដែលអាចកើតមានឡើង ។ ការបន្តកិច្ចសហការនេះ គឺជាកិច្ចខិតខំប្រឹងប្រែងដែលគួរឱ្យកោតសរសើរមួយក្នុងការជួយសម្រួលដល់ដំណើរការសវនាការប្រព្រឹត្តទៅយ៉ាងរលូន *(ក្រុមអ្នកឃ្លាំមើលតុលាការសូមធ្វើការកោតសរសើរ)* ។

***មេធាវីប្រឹក្សាយោបល់ផ្នែកច្បាប់សម្រាប់សាក្សី*** : នាសប្ដាហ៍នេះ លោកមេធាវី **គង់ សំអុន** បានបន្តវត្តមាននៅសវនាការ ដើម្បីផ្ដល់ប្រឹក្សាយោបល់ផ្នែកច្បាប់ដល់សាក្សី ។ លោកបានផ្ដល់ប្រឹក្សាយោបល់ និងធ្វើការបញ្ជាក់សាក្សីជាញឹកញាប់ អំពីអត្ថន័យនៃការមិនឆ្លើយដាក់ពិរុទ្ធភាពខ្លួនឯង ក៏ដូចជាធានាថា ភាគីទាំងអស់តាំងសំណួរក្នុងលក្ខខណ្ឌមួយ ដែលធ្វើឱ្យសាក្សីអាចយល់ដឹងបាន ។

## ៤. ការគ្រប់គ្រងសវនាការ

### *ការគ្រប់គ្រងរបស់តុលាការ*

***ការបត់បែនពេលម៉ោងបានកំណត់ :*** ដើម្បីឱ្យស្របតាមការប្រកាសខាងដើម អំពីការផ្ដល់ម៉ោងពេលបន្ថែមដល់មេធាវីការពារក្ដីទៅតាមភាពចាំបាច់ នៅថ្ងៃច័ន្ទ អង្គជំនុំជម្រះបានអនុញ្ញាតឱ្យមេធាវីការពារក្ដីសួរដេញដោលសាក្សី **សេក ជន** បន្ថែម ១០នាទីទៀត និងនៅថ្ងៃព្រហស្បតិ៍ កំឡុងពេលសួរដេញដោលសាក្សីជំនាញ **David Chandler** អង្គជំនុំជម្រះបានបន្ថែម ១៥នាទី ទៀតទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិតាមការស្នើសុំ ដើម្បីបញ្ចប់សំណួរខ្លួន ។ លក្ខខណ្ឌនេះក៏អនុវត្តផងដែរ ចំពោះការស្នើសុំរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ។ ក្រុមអ្នកឃ្លាំមើលតុលាការកត់សម្គាល់ថា មេធាវីការពារក្ដីបានប្រើប្រាស់ម៉ោងកំណត់លើសដោយពុំមានការបង្អាក់ពីសំណាក់ចៅក្រមទេ ។

***វត្តមានភាគី*** : កំឡុងកិច្ចដំណើរការនីតិវិធីនាសប្ដាហ៍នេះ លោក **Anees Ahmed** តំណាងសហព្រះរាជអាជ្ញារងអន្តរជាតិ នៅថ្ងៃច័ន្ទ ថ្ងៃអង្គារ និងថ្ងៃពុធ ប៉ុន្តែនៅ ថ្ងៃព្រហស្បតិ៍ តំណាងដោយលោក **William Smith** ។ សហព្រះរាជអាជ្ញាជាតិលោក **តាន់ សេណារ៉ុង** វត្តមាននៅថ្ងៃច័ន្ទ ថ្ងៃអង្គារ និងថ្ងៃព្រហស្បតិ៍ ប៉ុន្តែនៅថ្ងៃពុធ តំណាងដោយលោក **យ៉េត ចរិយា** ។

បន្ទាប់ពីអវត្តមានកាលពីសប្ដាហ៍មុន លោកមេធាវី **François Roux** មានវត្តមានក្នុងកិច្ចដំណើរការនីតិវិធីពេញមួយ

សប្ដាហ៍ ។ ទោះយ៉ាងណា លោកបានប្រកាសថា នៅសប្ដាហ៍ក្រោយ លោកនឹងអវត្តមាន ហើយជំនួសដោយលោកស្រី **Canizares** ។ ចំណែកលោកមេធាវី **ការ សាវុត្ថ** បន្តមានវត្តមានការពារជនជាប់ចោទ នាសប្ដាហ៍នេះ ។

***ការចូលរួមរបស់សាធារណៈជន*** : កិច្ចដំណើរការនីតិវិធីនាសប្ដាហ៍នេះ វត្តមានប្រជាពលរដ្ឋនៅតែបន្តចូលរួមដ៏ច្រើនកុះករ ដោយការរៀបចំ និងកម្មវិធីផ្សព្វផ្សាយរបស់អ.វ.ត.ក. ពីបណ្ដាខេត្តនានា ។ នៅថ្ងៃច័ន្ទ សវនាការមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋខ្មែរប្រមាណជា ៣៥០នាក់ មកពីឃុំផ្សេងៗក្នុងស្រុកបុរីជលសារ ខេត្តតាកែវ ។ នៅថ្ងៃអង្គារ ប្រជាពលរដ្ឋប្រមាណជា ៤០០នាក់ មកពីស្រុកគិរីវង្ស និងថ្ងៃពុធ ប្រមាណជា ៣០០នាក់ មកពីស្រុកកំពង់សៀម និងស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។ នៅថ្ងៃចុងក្រោយនៃកិច្ចដំណើរការនីតិវិធីនាសប្ដាហ៍នេះ មានប្រជាពលរដ្ឋចូលរួមប្រមាណ ៤០០នាក់ មកពីឃុំខុសៗគ្នាក្នុងស្រុកពួក ខេត្តសៀមរាប ។

## ***ឥរិយាបថនៅក្នុងបន្ទប់សវនាការ***

***សមត្ថភាពយល់ដឹងសាក្សីត្រូវលើកឡើង*** : ក្រុមអ្នកឃ្លាំមើលតុលាការបានសង្កេតឃើញថា ទាំងអង្គជំនុំជម្រះ និងមេធាវីប្រឹក្សាយោបល់សាក្សីហាក់បានវាយតម្លៃលើសមត្ថភាពយល់ដឹងរបស់សាក្សីក្នុងការឆ្លើយសំណួរ នាសប្ដាហ៍នេះ ។ ការលើកឡើងពីកង្វះការយល់ដឹង និងចំណេះដឹង ក្នុងការអាន ការសេរសេររបស់សាក្សី គឺជាចេតនាមួយដ៏ល្អ ប៉ុន្តែក៏ឆ្លុះបញ្ចាំងពីភាពអវិជ្ជមានចំពោះសាក្សី ។ ក្រុមអ្នកឃ្លាំមើលតុលាការ សូមផ្ដល់ជាអនុសាសន៍ថា អង្គជំនុំជម្រះ និងមេធាវីប្រឹក្សាយោបល់សាក្សី គួរទប់ស្កាត់ឬបញ្ចៀសការប្រើប្រាស់ភាសាបច្ចេកទេស និងពាក្យច្បាប់ នៅពេលលើកឡើងពីសមត្ថភាពសាក្សី ។ **<u>ឧទា :</u>** អង្គជំនុំជម្រះគួរសំអាងលើភាពចាំបាច់ក្នុងការយកចិត្តទុកដាក់នៅពេលតាំងសំណួរ ដូចជា "ដោយសារតែសាក្សីមិនសុំានឹងបន្ទប់សវនាការ..." ឬ "ដោយសារតែសាក្សីមានការលំបាកក្នុងការយល់ភាសាបច្ចេកទេសច្បាប់..." ជាជាងការលើកឡើងពីជំនាញជាក់លាក់របស់សាក្សី ។

***ការរំលឹកភាគីមិនឱ្យនិយាយមុនការអនុញ្ញាត*** : ប្រធានអង្គជំនុំជម្រះ បានរំលឹកដាច់អហង្កាជាថ្មីម្ដងទៀតដល់ភាគីមិនឱ្យនិយាយមុនផ្ដល់ការអនុញ្ញាត កាលពីព្រឹកថ្ងៃអង្គារ ។ កំឡុងពេលពិភាក្សាលើការប្រើប្រាស់កំណត់ហេតុស្ដាប់ចម្លើយធ្វើដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ថាជាឯកសារមូលដ្ឋានសម្រាប់សួរដេញដោលសាក្សី (សូមមើលផ្នែក *បញ្ហាច្បាប់ និងនីតិវិធី* នៃរបាយការណ៍នេះ) សហព្រះរាជអាជ្ញារងអន្តរជាតិ បានងើបឡើងប៉ុនប៉ងឆ្លើយតបលើការកត់សម្គាល់មេធាវីក្ដីការពារក្ដីអន្តរជាតិ ប៉ុន្តែមិនសុំអនុញ្ញាតពីប្រធានអង្គជំនុំជម្រះ ។ ករណីនេះ ប្រធានអង្គជំនុំជម្រះហាក់ខឹងសម្បារ និងដាស់តឿនដល់សហព្រះរាជអាជ្ញាឱ្យសុំការអនុញ្ញាតជាមុន ។ ក្នុងឱកាសនេះ ហាក់ដូចជាការត្រឹមត្រូវដែលអង្គជំនុំជម្រះបានលើកឡើង ព្រោះកិច្ចនីតិវិធីកំពុងដំណើរការយ៉ាងរលូន ហើយភាគីមិនគោរពវិន័យ ។

***សំលេងទូរស័ព្ទរោទិ៍ក្នុងបន្ទប់សាធារណៈ*** : បំរាមហាមមិនឱ្យយកទូរស័ព្ទចូលបន្ទប់សាធារណៈ មិនអនុវត្តឱ្យបានហ្មត់ចត់ទេនាសប្ដាហ៍នេះ ព្រោះមានសំលេងទូរស័ព្ទបានរោទិ៍ឡើងកំឡុងពេលកិច្ចដំណើរការនីតិវិធីនៅថ្ងៃច័ន្ទ ។ បញ្ហានេះបង្ហាញយើងថាវិធានសម្រាប់រក្សាសណ្ដាប់ធ្នាប់នៅសាលសាធារណៈមិនត្រូវបានអនុវត្តឱ្យបានល្អនោះទេ។

# ការគ្រប់គ្រងពេលវេលា

| ថ្ងៃ- កាលបរិច្ឆេទ | ចាប់ផ្តើម | សំរាក- ព្រឹក | អាហារថ្ងៃត្រង់ | សំរាក- រសៀល | បញ្ឈប់ | សរុបចំនួនម៉ោង |
|---|---|---|---|---|---|---|
| ច័ន្ទ ០៣-០៨-០៩ | ០៩:០០ | ១០:៣៥-១១:០៥ | ១២:០៥-១៣:៣៥ | ១៤:៤០-១៥:០៣ | ១៦:១៥ | ៤ម៉ ៥២នាទី |
| អង្គារ៍ ០៤-០៨-០៩ | ០៩:០៥ | ១០:៣៧-១០:៥៧ | ១២:១០-១៣:៣៥ | ១៤:៤០-១៥:០០ | ១៦:១២ | ៥ម៉ ១២នាទី |
| ពុធ ០៥-០៨-០៩ | ០៩:០០ | ១០:៤០-១១:០០ | ១២:០៥-១៣:៣០ | ១៤:៤០-១៥:២០ | ១៦:១៥ | ៤ម៉ ៤០នាទី |
| ព្រហ. ០៦-០៨-០៩ | ០៩:០០ | ១០:៤០-១០:៥៥ | ១១:៥០-១៣:៣០ | ១៤:៣០-១៤:៥០ | ១៦:១៥ | ៥ម៉ ០០នាទី |

ចំនួនម៉ោងជាមធ្យម : ៤ម៉ ៥៦ នាទី

ចំនួនម៉ោងសរុបនាសប្តាហ៍នេះ : ១៩ម៉ ៤៤នាទី

ចំនួនសរុប ម៉ោង ថ្ងៃ និង សប្តាហ៍ នៅសវនាការ : ២៣៥ម៉ ១៤នាទី នៃ ៥៤ ថ្ងៃសវនាការ នៃសប្តាហ៍ទី ១៥

---

**អំពីកម្មវិធីអ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម** ("កម្មវិធី") : ជាកម្មវិធីរបស់អង្គការ the Asian International Justice Initiative (AIJI) ដែលជាកិច្ចសហការណ៍រវាង U.C. Berkeley War Crimes Studies Center និង East-West Center ។

កម្មវិធីនេះចេញរបាយការណ៍ប្រចាំសប្តាហ៍ អំពីកិច្ចដំណើរការនីតិវិធីសវនាការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ឬតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ បច្ចុប្បន្ន កម្មវិធីនេះកំពុងតែឃ្លាំមើលដំណើរការនៃការកាត់ទោសលើសំណុំរឿង **កាំង ហ្គិចអ៊ាវ** ហៅ **ឌុច** ដែលជារឿងក្តីដំបូងឈានដល់ដំណាក់កាលជំនុំជម្រះ ។

របាយការណ៍ប្រចាំសប្តាហ៍នេះ ត្រូវបានរៀបចំដោយក្រុមឃ្លាំមើលតុលាការ ដែលដឹកនាំដោយលោកស្រី **Michelle Staggs** ជានាយិការងនៃអង្គការ AIJI ដែលមានសមាសភាពដូចខាងក្រោម :

**ក្រុមទី១**
- លោកស្រី **ជូ វិនាថ** : ប្រធានកម្មវិធីសង្កេតការណ៍តុលាការនៃ CSD
- លោក **ង៉ែត សុវណ្ណនិត** : បុគ្គលិកអង្គការ KID
- កញ្ញា **Yvette Anthony** : សិង្ហបុរី
- លោក **Florian Hansen** : អាល្លឺម៉ង់
- កញ្ញា **Caroline Ehlert Zurich** : ស្វីស
- កញ្ញា **Deepika Sharma** : សហរដ្ឋអាមេរិក

**ក្រុមទី២**
- កញ្ញា **សេក សុវណ្ណា** : មេធាវី អង្គការ CLEC
- លោក **ភ័ក្រ្ត សារិន** : បុគ្គលិកអង្គការ UNOHCHR
- កញ្ញា **Aviva Nababan** : ឥណ្ឌូនេស៊ី
- កញ្ញា **Romana Weber** : ស្វីស
- កញ្ញា **Binxin Zhang** : ចិន
- លោក **Jaspreet Dosanjh** : សហរដ្ឋអាមេរិក

កម្មវិធីនេះ បានសហការជាមួយមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (CSD) និង (KID) ដើម្បីផ្សព្វផ្សាយរបាយការណ៍នេះ ។ លោក-អ្នកអាចរកបាននូវរបាយការណ៍នេះជាភាសាខ្មែរ និងអង់គ្លេស នៅក្នុង www.csdcambodia.org ; www.kidcambodia.org និង http://Socrates.berkeley.edu/-warcrime/_ ។